ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

# សេចក្ដីណែនាំ
# ស្ដីពី
# វិធានការបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ ១៩

យោងសារាចរណែនាំលេខ០១ សរណន ចុះថ្ងៃអាទិត្យ ៧រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០ ស្ដីពីវិធានការបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ១៩ ក្រសួងសូមធ្វើការណែនាំដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ទាំងអស់ ក្រោមឱវាទក្រសួងពាណិជ្ជកម្ម ដូចខាងក្រោម៖

១. ផ្អាកការធ្វើដំណើរទៅចូលរួមកិច្ចប្រជុំ សិក្ខាសាលា ឬវគ្គបណ្ដុះបណ្ដាលនានានៅក្រៅប្រទេស ជាពិសេសគឺការធ្វើដំណើរទៅកាន់បណ្ដាប្រទេសនៅអឺរ៉ុប សហរដ្ឋអាមេរិក និងអ៊ីរ៉ង់ លើកលែងតែមានការអនុញ្ញាតពិសេស ឬការចាំបាច់បំផុតណាមួយដោយខានពុំបាន

២. ផ្អាកការទទួលជួបភ្ញៀវបរទេស និងភ្ញៀវនានា ហើយប្រសិនបើចាំបាច់បំផុតខានពុំបាន គឺត្រូវធ្វើតាវកិច្ចតាមរយៈលើកដៃសំពះជៀសវាងការចាប់ដៃ និងត្រូវរក្សាចម្ងាយ ១,៥ម៉ែត្រពីភ្ញៀវ ហើយត្រូវលាងដៃសម្លាប់មេរោគតាមការចាំបាច់

៣. បើពុំមានការចាំបាច់ ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន នាយកដ្ឋាន ឬអង្គភាពក្រោមឱវាទទាំងអស់ អាចអនុញ្ញាតឱ្យមន្ត្រីរបស់ខ្លួនបំពេញការងារនៅផ្ទះតាមប្រព័ន្ធអនឡាញ(Online)បាន ប៉ុន្តែត្រូវរៀបចំមន្ត្រីប្រចាំការជាប់ជាប្រចាំ ដើម្បីធានានូវដំណើរការនៃការផ្ដល់សេវាសាធារណៈជូនអតិថិជនតាមផ្នែកនីមួយៗ ប្រកបដោយប្រសិទ្ធភាពនិងការទទួលខុសត្រូវខ្ពស់

៤. ចំពោះមន្ត្រីរាជការណាដែលបានត្រឡប់មកពីការបំពេញបេសកកម្មក្រៅប្រទេសវិញ ជាពិសេសគឺមន្ត្រីរាជការដែលទើបត្រឡប់មកពីបណ្ដាប្រទេសនៅអឺរ៉ុប សហរដ្ឋអាមេរិក និងអ៊ីរ៉ង់ គឺត្រូវដាក់ខ្លួនឱ្យនៅដាច់ដោយឡែកក្នុងរយៈពេល១៤ថ្ងៃ គិតចាប់ពីថ្ងៃដែលបានត្រឡប់មកដល់ព្រះរាជាណាចក្រកម្ពុជាវិញ ស្របតាមនីតិវិធីកំណត់ដោយក្រសួងសុខាភិបាល។ ករណីនេះដែរ សាមីខ្លួនអាចបន្តការងាររបស់ខ្លួនតាមប្រព័ន្ធអនឡាញ(Online) ហើយត្រូវជូនដំណឹងមកនាយកដ្ឋានបុគ្គលិកដើម្បីធ្វើការកត់ត្រា និងសម្របសម្រួល

៥. បង្កើនវិធានការអនាម័យឱ្យមានប្រសិទ្ធភាពខ្ពស់ ជាពិសេសត្រូវលាងសម្អាតដៃជាមួយនឹងសាប៊ូ ឬទឹកលាងសម្លាប់មេរោគ ជាប់ជាប្រចាំត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសចាំបាច់។

ក្រសួងសង្ឃឹមជឿជាក់ថា ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាមន្ត្រីរាជការ គ្រប់លំដាប់ថ្នាក់ទាំងអស់ ក្រោមឱវាទក្រសួងពាណិជ្ជកម្ម នឹងអនុវត្តតាមសេចក្ដីណែនាំនេះប្រកបដោយប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃចន្ទ ៨រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469